ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

លេខ :

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកំណត់ថ្លៃសំរាប់ការបង់ថ្លៃចុះបញ្ជី ពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការ ពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

## សម្រេច

**ប្រការ ១ :**

រូបវ័ន្តបុគ្គល ឬ នីតិបុគ្គលដែលដាក់ពាក្យសុំ ឬសម្បទានិកដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបង់ជូនរដ្ឋ នូវថ្លៃចុះបញ្ជី ពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែនៅអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ថ្លៃចុះបញ្ជី ពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម :

### ១.១ ថ្លៃចុះបញ្ជី

| | | |
|---|---|---|
| ១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ .................................. | ៤០.០០០ | (សែសិបពាន់) រៀល |
| ២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ : | | |
| ២-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ.......................... | ៤០០.០០០ | (បួនរយពាន់) រៀល |
| ២-២ ថ្មសំណង់, ថ្មអារ, ក្រួស, ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ........ | ៨០០.០០០ | (ប្រាំបីរយពាន់) រៀល |
| ៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ...................... | ២.០០០.០០០ | (ពីរលាន) រៀល |
| ៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ........................................ | ៤០០.០០០ | (បួនរយពាន់) រៀល |
| ៥- អាជ្ញាប័ណ្ណស្វែងរុករក ............................................ | ៨០០.០០០ | (ប្រាំបីរយពាន់) រៀល |
| ៦- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ................ | ១.២០០.០០០ | (មួយលានពីររយពាន់) រៀល |

### ១.២ ថ្លៃពាក្យសុំ(កម្រៃអាជ្ញាប័ណ្ណ)

| | | |
|---|---|---|
| ១- អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែ .................................. | ៥០.០០០ | (ហាសិបពាន់) រៀល |
| ២- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ : | | |
| ២-១ ខ្សាច់សំណង់, ឡាតេរីត, ដីឥដ្ឋ.......................... | ៦០០.០០០ | (ប្រាំមួយរយពាន់) រៀល |
| ២-២ ថ្មសំណង់, ថ្មអារ, ក្រួស, ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល ....... | ១.៦០០.០០០ | (មួយលានប្រាំមួយរយពាន់) រៀល |
| ៣- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ...................... | ៨.០០០.០០០ | (ប្រាំបីលាន) រៀល |
| ៤- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន : | | |
| ៤.១- កំលាំងពលកម្មតិចជាង៧នាក់ .......................... | ៨០០.០០០ | (ប្រាំបីរយពាន់) រៀល |
| ៤.២- កំលាំងពលកម្ម ពី៧នាក់ ទៅ១៤ នាក់ ............. | ១.៦០០.០០០ | (មួយលានប្រាំមួយរយពាន់) រៀល |

| | | |
|---|---|---|
| ៤.៣- កំលាំងពលកម្មលើសពី ១៤ នាក់ ..................... | ៣.២០០.០០០ | (បីលានពីររយពាន់) រៀល |
| ៥- អាជ្ញាប័ណ្ណស្វែងរុករក ............................................ | ៦.០០០.០០០ | (ប្រាំមួយលាន) រៀល |
| ៦- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ............... | ១២.០០០.០០០ | (ដប់ពីរលាន) រៀល |

## ១.៣ ថ្លៃពន្យារបន្ត

| | | |
|---|---|---|
| ១- អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ : | | |
| ១-១ ខ្សាច់សំណង់. ឡាតេរីត. ដីឥដ្ឋ.................. | ៤២០.០០០ | (បួនរយម្ភៃពាន់) រៀល |
| ១-២ ថ្មសំណង់. ថ្មអារ. ក្រួស.ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល .. | ១.១២០.០០០ | (មួយលានមួយរយម្ភៃពាន់) រៀល |
| ២- អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ ............... | ៥.៦០០.០០០ | (ប្រាំលានប្រាំមួយរយពាន់) រៀល |
| ៣- អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន : | | |
| ៣.១- កំលាំងពលកម្មតិចជាង៧នាក់ ................ | ៥៦០.០០០ | (ប្រាំរយហុកសិបពាន់) រៀល |
| ៣.២- កំលាំងពលកម្ម ពី៧ នាក់ ទៅ១៤ នាក់ ...... | ១.១២០.០០០ | (មួយលានមួយរយម្ភៃពាន់) រៀល |
| ៣.៣- កំលាំងពលកម្មលើសពី ១៤ នាក់ ............ | ២.២៤០.០០០ | (ពីរលានពីររយសែសិបពាន់) រៀល |
| ៤- អាជ្ញាប័ណ្ណស្វែងរុករក...................................... | ៤.២០០.០០០ | (បួនលានពីររយពាន់) រៀល |
| ៥- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ........ | ៨.៤០០.០០០ | (ប្រាំបីលានបួនរយពាន់) រៀល |

## ១.៤ ថ្លៃផ្ទេរសិទ្ធិ

| | | |
|---|---|---|
| ១-អាជ្ញាប័ណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្ម សំរាប់ : | | |
| ១-១ ខ្សាច់សំណង់. ឡាតេរីត. ដីឥដ្ឋ................... | ២.០០០.០០០ | (ពីរលាន) រៀល |
| ១-២ ថ្មសំណង់. ថ្មអារ. ក្រួស. ម្នាងសិលា និងថ្មផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា .. | ៨.០០០.០០០ | (ប្រាំបីលាន) រៀល |
| ២-អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ .............. | ១៦.០០០.០០០ | (ដប់ប្រាំមួយលាន) រៀល |
| ៣-អាជ្ញាប័ណ្ណកែច្នៃធនធានរ៉ែ ដែលមាន : | | |
| ៣.១- កំលាំងពលកម្មតិចជាង៧នាក់ ................ | ២.០០០.០០០ | (ពីរលាន) រៀល |
| ៣.២- កំលាំងពលកម្ម ៧នាក់ - ១៤ នាក់ ........... | ៤.០០០.០០០ | (បួនលាន) រៀល |
| ៣.៣- កំលាំងពលកម្មលើសពី ១៤ នាក់ ............. | ៦.០០០.០០០ | (ប្រាំមួយលាន) រៀល |
| ៤- អាជ្ញាប័ណ្ណស្វែងរុករក...................................... | ២០.០០០.០០០ | (ម្ភៃលាន) រៀល |
| ៥- អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ......... | ២៤.០០០.០០០ | (ម្ភៃបួនលាន) រៀល |

## ប្រការ ២ :

ការគ្រប់គ្រងចំណូលដែលបានមកពីការបង់ថ្លៃចុះបញ្ជី ពាក្យសុំ (កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ ។

## ប្រការ ៣ :

ប្រាក់ចំណូលដែលបានមកពីការបង់ថ្លៃចុះបញ្ជី ពាក្យសុំ (កម្រៃអាជ្ញាប័ណ្ណ) ការពន្យារបន្ត និងការផ្ទេរសិទ្ធិនៃអាជ្ញាប័ណ្ណធនធានរ៉ែត្រូវបង់ចូលថវិការដ្ឋទាំងស្រុង ដោយកត់ត្រាក្នុងជំពូក៧២ គណនី៧២០ អនុគណនី៧២០៤ ។

មួយផ្នែកនៃប្រាក់ចំណូលខាងលើ និងនីតិវិធីនៃការដកប្រាក់នេះ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលគោលការណ៍យល់ព្រមពីរាជរដ្ឋាភិបាល សំរាប់ចាត់ចែងចំណាយលើការងារដូចខាងក្រោម :

១- រៀបចំឯកសារចុះបញ្ជី វិញ្ញាបនប័ត្រចុះបញ្ជី និងអាជ្ញាប័ណ្ណធនធានរ៉ែ

២- ចុះពិនិត្យទីស្នាក់ការ និងទីតាំងស្នើសុំធ្វើការស្វែងរុករក និងអាជីវកម្មរ៉ែរបស់ក្រុមហ៊ុន ឬ អាជីវករនៅតាមបណ្តាខេត្ត-ក្រុង ។

៣- កសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃការចុះបញ្ជី និងសុពលភាពនៃអាជ្ញាប័ណ្ណធនធានរ៉ែ ។

៤- ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ។

## ប្រការ ៤ :

នៅរៀងរាល់ដំណាច់ខែនីមួយៗ អគ្គនាយកដ្ឋានធនធានរ៉ែត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ( នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) និងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល( នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ) អំពីចំណូលដែលបានបង់ចូលថវិការដ្ឋ ដោយថតចម្លង និងភ្ជាប់មកជាមួយនូវសលាកប័ត្របង់ចំណូលទាំងអស់ ។

## ប្រការ ៥ :

អង្គភាពពាក់ព័ន្ធក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ព្រមទាំងរូបវ័ន្តបុគ្គល នីតិបុគ្គល ឬសម្បទានិកដូចក្នុងប្រការ១ ដែលមានអាជ្ញាប័ណ្ណធនធានរ៉ែ ត្រូវទទួលបន្ទុកអនុវត្ត តាមប្រកាសនេះ។

## ប្រការ ៦ :

ប្រកាសនេះមានប្រសិទ្ធភាព និងចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ចម្លងជូន :
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង ( ដើម្បីជូនជ្រាប)
- ដូចប្រការ ៥ ( ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ